ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

SOCIAL PROTECTION IN CAMBODIA

*ថ្ងៃ ពុធ ១១ កើត ខែ ផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៤*

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី១១

នៅថ្ងៃ ពុធ ១១ កើត ខែ ផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៤, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី ១១ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ដែលជាអនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងក្រុមការងារពាក់ព័ន្ធ ។ កិច្ចប្រជុំ មានគោលបំណង ពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាង "**ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា**" មុននឹងគោរពស្នើសុំការពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ជាសារបាន, "**ការគ្របដណ្ដប់សុខភាពជាសកល (គ.ស.ស.)**" គឺជាការប្ដេជ្ញារបស់ប្រទេសនានាដែលជាសមាជិកនៃអង្គការសុខភាពពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ ក្នុងការផ្ដល់សេវាថែទាំសុខភាពដែលមានគុណភាព ប្រកបដោយសមធម៌ដល់ពលរដ្ឋគោលដៅ ដោយមិនបារម្ភពីបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ។ ដើម្បីសម្រេចគោលដៅនេះ, រាជរដ្ឋាភិបាល បានរំលេចទិដ្ឋភាពនៃ "ការគ្របដណ្ដប់សុខភាពជាសកល" ជាធាតុស្នូលនៅក្នុងឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយជាតិមួយចំនួន ដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣, ផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០០៨-២០១៥ និង ២០១៦-២០២០, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, និងក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ ជាដើម ។ ក្នុងន័យនេះ, ដើម្បីជំរុញកិច្ចការនេះ, រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បានកំណត់ "**ការពង្រឹកសេវាថែទាំសុខភាពឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា**" ជាកម្មវិធីគោលនយោបាយអាទិភាពទី ១ ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ ផងដែរ ។

"**សេចក្ដីព្រាងផែនទីបង្ហាញផ្លូវ**" នេះ បានកំណត់ជម្រើសគោលនយោបាយអាទិភាពសម្រាប់កែទម្រង់ប្រព័ន្ធគាំពារសុខភាពសង្គម និងប្រព័ន្ធសុខាភិបាល ក្នុងទិដ្ឋភាពពហុវិស័យ, ពហុវិមាត្រ, និងគ្រប់ជ្រុងជ្រោយ ដោយបង្ហាញទិសដៅ និងបង្គោលចរកម្រិតយុទ្ធសាស្ត្រ ដែលក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធមានភារកិច្ចរៀបចំផែនការលម្អិតសម្រាប់ការអនុវត្ត ។

ជាលទ្ធផល, អង្គប្រជុំបានពិនិត្យ និងបានកែសម្រួល "**សេចក្ដីព្រាងផែនទីបង្ហាញផ្លូវឆ្ពោះទៅ គ.ស.ស.**" ដោយកំណត់អំពីការដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រ និងគោលដៅអាទិភាពទៅតាមដំណាក់កាលសំដៅពង្រីកជាជំហានៗ នូវវិសាលភាពនៃការគ្របដណ្ដប់ពលរដ្ឋ, ការគ្របដណ្ដប់សេវាសុខាភិបាលសារវន្ត, និងការការពារហានិភ័យហិរញ្ញវត្ថុ និងហិរញ្ញប្បទានសុខាភិបាល ។